**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃចន្ទ ៣រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤។

**២. ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣-១-ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម យិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣២រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣៤រូប សរុបចំនួន៦៦រូប។

**៤. របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម យិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ បទបង្ហាញស្តីពី "ផ្សព្វផ្សាយលទ្ធផលសេចក្តីសម្រេចក្នុងកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៤" ដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤.៣ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម យិនជារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងនូវមតិស្វាគមន៍ដល់ក្រុមការងារ និងអង្គប្រជុំ ដោយបានថ្លែងនូវការកោតសរសើរក្រុមការងារ ក៏ដូចជាក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍កន្លងមក ដែលបង្កឱ្យអត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅកម្ពុជា បានធ្លាក់ចុះជាបន្តបន្ទាប់មកនៅត្រឹមតែ ០,៥% នៅឆ្នាំ២០២២។ **ឯកឧត្តមបណ្ឌិត** បានបើកនូវ "កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៤"។

**កិច្ចប្រជុំមានគោលបំណង ដូចខាងក្រោម៖**

១-ពិនិត្យនូវសេចក្តីសម្រេច របស់កិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៤

២- ផែនការអនុវត្តនូវសេចក្តីសម្រេច របស់កិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៤

៣- ផ្សេងៗ

**ឯកឧត្តមបណ្ឌិត** ក៏បានបញ្ជាក់ពីសេចក្តីសម្រេចរបស់កិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៤ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីកន្លងទៅ ព្រមលើកយកមកពិភាក្សា ដើម្បីអាចឱ្យក្រុមការងារបច្ចេកទេសយល់ដឹងច្បាស់លាស់ និងដាក់នូវផែនការអនុវត្ត ដើម្បីឈានសម្រេចឱ្យបាននូវសេចក្តីសម្រេចនេះ។

ក្នុងឱកាសនេះផងដែរ **ឯកឧត្តមបណ្ឌិត** បានលើកនូវអភិក្រមនៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។ គោលនយោបាយជាតិនេះ មានឆន្ទៈយកប្រជាពលរដ្ឋជាគោល និងមានគោលបំណង៖

១- កាត់បន្ថយការចម្លងថ្មីតិចជាង ១នាក់ ឬប្រមាណជា ២០០នាក់ ក្នុងមួយឆ្នាំ។

២- កាត់បន្ថយការស្លាប់ដោយសារមេរោគអេដស៍ ឱ្យនៅក្រោម ២០០នាក់ ក្នុងមួយឆ្នាំ។

៣- លុបបំបាត់ការមាក់ងាយ និងរើសអើង។

ទន្ទឹមនឹងនោះ **ឯកឧត្តមបណ្ឌិត** បានរំលឹកឡើងវិញ នូវផែនការយុទ្ធសាស្ត្រជាតិ ទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៤-២០២៨ ដែលមានចក្ខុវិស័យ៖ ប្រជាពលរដ្ឋកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងមានផលិតភាព មានសិទ្ធិពេញលេញ គ្មានមេរោគអេដស៍ និងជំងឺអេដស៍ និងគ្មានការមាក់ងាយ រើសអើង និងមានបេសកកម្ម ធានាបាននូវការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍បានល្អ ដោយមានការចូលរួមប្រកបដោយបរិយាបន្នដោយមូលដ្ឋាន និងសហគមន៍ជាម្ចាស់ ផ្តោតលើប្រជាពលរដ្ឋជាធំ មានភាពធន់ និងមានចីរភាព ដោយមានគោលដៅ៖ ការឆ្លើយតបនឹងមេរោគអេដស៍ជាពហុវិស័យប្រកបដោយចីរភាព ដែលធានាថាជំងឺអេដស៍លែងជាការគំរាមកំហែងសុខភាពសាធារណៈចាប់ពីឆ្នាំ២០២៨។ ផែនការយុទ្ធសាស្ត្រនេះ មានការគាំទ្រដោយគោលបំណងចំនួន៤ ដូចជា៖

១- ផ្តល់ការបង្ការ ព្យាបាល ថែទាំ និងគាំទ្រទូលំទូលាយ និងមានប្រសិទ្ធភាព តាមរយៈការសម្របសម្រួលល្អ និងប្រើប្រាស់វិធីសាស្ត្រជំរុញការចូលរួមជាពហុវិស័យ។

២- ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គម និងបង្កើតបរិយាកាសអំណោយផលឱ្យក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ បានទទួលសេវាមេរោគអេដស៍ សេវាសុខាភិបាល និងសេវាគាំទ្រផ្នែកច្បាប់ ព្រមទាំងសង្គមផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។

៣- កសាងសមត្ថភាពស្ថាប័ន សហគមន៍ និងបុគ្គល ដើម្បីពង្រឹងការឆ្លើយតបដោយសហគមន៍ និងកែលម្អការធ្វើសមាហរណកម្មឆ្លើយតបនឹងមេរោគអេដស៍ក្នុងវិស័យសុខាភិបាល និងមិនមែនសុខាភិបាល។

៤-ធានាចីរភាពសមិទ្ធផលជាតិនៃការឆ្លើយតបនឹងមេរោគអេដស៍ ដោយការបង្កើន ការវិនិយោគជាតិ និងការពង្រឹងប្រព័ន្ធប្រទេសឆ្លើយតបនឹងមេរោគអេដស៍ដោយអភិបាលកិច្ច សម្របសម្រួល និងត្រួតពិនិត្យ។

**ឯកឧត្តមបណ្ឌិត** ក៏បានផ្តល់នូវមតិ និងអនុសាសន៍ដល់កិច្ចប្រជុំដូចខាងក្រោម៖

- សូមប្រញាប់ប្រញាល់ ទៅបញ្ជូនជនរងគ្រោះដោយករណីរំលោភ ទៅធ្វើតេស្តរកមេរោគអេដស៍ ដើម្បីអាចឱ្យបង្ការបាននូវការចម្លងមេរោគអេដស៍ តាមរយៈកម្មវិធីបង្ការឆ្លងមេរោគអេដស៍ក្រោយការប្រឈម។
- គោរពនូវគោលការណ៍នៃការឆ្លើយតបនឹងមេរោគអេដស៍ ដែលរួមមាន៖ ភាពជាអ្នកដឹកនាំ ឬភាពជាម្ចាស់ ភាពជាដៃគូ និងការវិនិយោគ
  - ភាពជាម្ចាស់ឬភាពជាអ្នកដឹកនាំ សំដៅដល់គំនិតផ្តួចផ្តើម ការសម្របសម្រួល ការតម្រង់ទិស ការកែលម្អ ការបំពេញបន្ថែមលើចំណុចខ្វះខាត និងការត្រួតពិនិត្យវាយតម្លៃដែលរាជរដ្ឋាភិបាលដាក់ចេញ។
  - ភាពជាដៃគូ សំដៅដល់កិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍ ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ឬសង្គមស៊ីវិល ក្រុមប្រជាជនប្រឈមមុខក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ព្រោះបើគ្មានការចូលរួមពីដៃគូអភិវឌ្ឍន៍ និងក្រុមអ្នកទទួលផលពីកម្មវិធីនោះទេ ការឆ្លើយតបនេះនឹងមិនសម្រេចបានជោគជ័យឡើយ។
  - ការវិនិយោគ សំដៅដល់ការបោះទុនគាំទ្រកម្មវិធីអេដស៍ បើគ្មានធនធានសមស្របទេ កម្មវិធីនោះ ក៏មិនអាចសម្រេចជោគជ័យបាន។ ម្យ៉ាងទៀត ភាពជាដៃគូក៏មានទិសដៅទាក់ទាញឱ្យដៃគូទាំងនោះបោះទុន ជួយផ្តល់ធនធានហិរញ្ញវត្ថុ និងជំនាញដល់កម្មវិធីអេដស៍ដែរ ទើបកម្មវិធីនោះទទួលជោគជ័យ។
- ស្នើសុំឱ្យសមាជិកទាំងអស់ បញ្ចូលទៅក្នុងក្រុមណាមួយនៃក្រុមយុទ្ធសាស្ត្រជាតិទាំងប្រាំ ដើម្បីអនុវត្តនូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ ជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈដែលបានគ្រោងទុក និងបញ្ចប់នៅវេលាម៉ោង ១០ព្រឹក ថ្ងៃខែឆ្នាំដដែល ប្រកបដោយលទ្ធផលផ្លែផ្កា។ ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** បានជូនពរដល់សមាជិកអង្គប្រជុំ ឱ្យជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤

បានពិនិត្យត្រឹមត្រូវ

ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

**វេជ្ជ. ហួត សេរីវុធ**

អ្នកធ្វើរបាយការណ៍

**ស៊ុំ ផល្លា**

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ

**បណ្ឌិត ឈឹម យឺនដារ៉េត**